Media Release

Cambodia • Lao PDR • Thailand • Viet Nam
For sustainable development

សម្រាប់ការចេញផ្សាយបន្ទាន់

# ទឹកទន្លេមេគង្គអាចប្រែពណ៌ខៀវបៃតងនៅតាមកន្លែងផ្សេងៗ ដោយសារលំហូរទឹកទាប ដែលអាចបង្កឲ្យមានហានិភ័យ

**ទីក្រុងវៀងចន្ទ ប្រទេសឡាវ ថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៩ –** គណៈកម្មការទន្លេមេគង្គ (ដែលហៅកាត់ថា MRC) បានលើកឡើងថា លំហូរទឹកទាបខ្លាំង ការធ្លាក់ចុះឃើតនៃសារជាតុកករទន្លេ ទឹកថ្លានិងវត្តមានសារាយឬស្លែរនៅលើដីខ្សាច់ និងស្រទាប់បាតទន្លេគឺជាមូលហេតុដែលបណ្តាលឲ្យពណ៌ទឹកទន្លេមេគង្គប្រែជាពណ៌ខៀវបៃតងនាពេលថ្មីៗនេះ។ បាតុភូតនេះអាចនឹងរាលដាលដល់ផ្នែកទន្លេផ្សេងទៀតដែលមានលំហូរទឹកទាប។

នាពេលថ្មីៗនេះ ទឹកទន្លេមេគង្គក្នុងតំបន់ណាខន ផាណុម ប្រទេសថៃ និងខេត្តថាខែក ប្រទេសឡាវបានប្រែពណ៌ខៀវបៃតង។ យោងតាមការវិភាគទិន្នន័យបឋមរបស់ MRC លើមូលហេតុ និងផលប៉ះពាល់ដែលអាចមានពីបាតុភូតនេះ បានបង្ហាញថា បាតុភូតនេះកើតមានដោយសារកត្តាជាច្រើន ហើយផលវិបាករបស់វាអាចនឹងបង្កនូវបញ្ហាយ៉ាងច្រើន។

ការវិភាគនេះបានបង្ហាញថា លំហូរទឹកទាបខ្លាំងដែលទន្លេមេគង្គកំពុងជួបប្រទះនាពេលនេះ និងក្នុងកំឡុងពេលគ្រោះរាំងស្ងួតដ៏អាក្រក់បំផុតមួយដែលបានកើតឡើងក្នុងតំបន់ បានកែប្រែពណ៌ទឹកទន្លេនេះ។ ជាទូទៅសារជាតុកករទន្លេដែលធ្វើឲ្យទឹកទន្លេមានពណ៌ត្នោត ត្រូវបានប្រទះឃើញនៅក្នុងលំហូរទឹកលឿន និងក្នុងកម្រិតទឹកជ្រៅ។ ការបាត់បង់សារជាតុកករទាំងនេះធ្វើឲ្យទឹកមានសភាពថ្លាជាងមុន។

ការវិភាគបានបន្ថែមថា នេះមានន័យថានៅពេលដែលពន្លឺព្រះអាទិត្យជះលើទឹកទន្លេ ទឹកទន្លេនឹងស្រូបយកយ៉ាងច្រើននូវអ្វីដែលគេស្គាល់ថាជា "រលកពណ៌ដែលមានចម្ងាយវែង" (long-wavelength colors) នៅខាងចុងពណ៌ក្រហមនៃវិសាលគមពន្លឺ ដែលធ្វើឲ្យទឹកទន្លេមានពណ៌ខៀវ។ កត្តានេះកើតឡើងចំពោះទឹកដែលមានជម្រៅរាក់ប្រមាណ១ឬ២ម៉ែត្រ។

យោងតាមការវិភាគបឋម ទឹកកាន់តែថ្លាអនុញ្ញាតឲ្យរុក្ខជាតិមីក្រូទស្សន៍ (ល្អិតៗ) ឬសារាយដុះលើដីខ្សាច់ និងស្រទាប់បាតទន្លេ ដែលបង្កឲ្យរឹមទន្លេប្រែពណ៌បៃតង។ សារាយទាំងនេះជាទូទៅត្រូវបានសំអាតដោយចរន្តទឹក។ ប៉ុន្តែដោយសារតែលំហូរទឹកទាប ស្ថានភាពសំអាតនេះមិនបានកើតមាននៅទន្លេមេគង្គក្នុងតំបន់ណាខនផាណុម ឬតាមកន្លែងឯទៀតនោះទេ។ ផ្ទុយមកវិញ សារាយបន្តដុះលូតលាស់យ៉ាងច្រើន។

ការវិភាគបានផ្តល់ព័ត៌មានថា លក្ខខណ្ឌទាំងនេះអាចនឹងប្រែកាន់តែអាក្រក់ ប្រសិនបើមានការបង្ហូរជីកសិកម្មចូលទៅក្នុងទន្លេ ដែលវាចិញ្ចឹមសារាយឲ្យកាន់តែលូតលាស់ច្រើនថែមទៀត។

លោកបណ្ឌិត សូ ណាម ប្រធានមន្ត្រីផ្នែកគ្រប់គ្រងបរិស្ថានMRC ដែលដឹកនាំការវិភាគបានមានប្រសាសន៍ថា “បាតុភូតទឹកពណ៌ខៀវបៃតង អាចនឹងរាលដាលដល់តំបន់ទន្លេមេគង្គផ្សេងៗទៀតដែលមានលំហូរទឹកទាប។ បញ្ហាលំហូរទឹកទាប និងកករទន្លេអាចនឹងបង្កឲ្យមានផលប៉ះពាល់អវិជ្ជមាន ដូចដែលបានបង្ហាញយ៉ាងច្រើននៅក្នុងរបាយការណ៍នៃការសិក្សាក្រុមប្រឹក្សារបស់MRC។”

ផលប៉ះពាល់ដែលអាចកើតឡើងរួមមាន បម្រែបម្រួលផលិតភាពរបស់ទន្លេក្នុងការបង្កើតអាហារឲ្យបានគ្រប់គ្រាន់សម្រាប់សត្វ និងកូនត្រីតូចៗ ផលិតភាពជីវៈសាស្ត្រចម្រុះក្នុងទឹកត្រូវបានកាត់បន្ថយ រួមទាំងត្រីដោយសារទឹកប្រែកាន់តែថ្លាច្បាស់។ ស្ថានភាពនេះផ្ទុយមកវិញ នឹងប៉ះពាល់ដល់ការប្រមូលផលត្រី និងការប្រកបរបរចិញ្ចឹមជីវិតរបស់សហគមក្នុងស្រុក។

ស្ថានភាពទឹកថ្លាក៏បណ្តាលឲ្យមានកំណើនសារាយគួរឲ្យកត់សម្គាល់ ឬបរិមាណសារាយច្រើនលើសលប់។ វាបង្កឲ្យកម្រិតអុកស៊ីសែនលោយខ្ពស់ ក្នុងកំឡុងពេលថ្ងៃ ប៉ុន្តែភាពរំលាយមានសភាពទាបនៅពេលយប់។ ស្ថានភាពនេះអាចប៉ះពាល់ដល់អាយុជីវិតត្រីនានា នេះបើយោងតាមការវិភាគ។

ការវិភាគបានបន្ថែមទៀតថា ប្រសិនបើស្ថានភាពទឹកថ្លានៅតែបន្ត កំណើនសារាយអាចបង្កើតកម្រាលពណ៌បៃតងកាន់តែក្រាស់ ដែលនឹងប្រែរលួយ និងមានក្លិនមិនល្អ។ ហើយប្រសិនបើស្ថានភាពនេះប្រែកាន់តែអាក្រក់ ប្រភេទស្លែរ ពណ៌បៃតង (Chlorophyceae) អាចប្រែទៅជាប្រភេទស្លែរពណ៌ខៀវ (Cyanophyceae) ដែលអាចបង្កើតសារជាតុពុលប៉ះពាល់ដល់សត្វពាហនៈនានា។

ប៉ុន្តែលោកណាម បានលើកឡើងថា “ស្ថានភាពបែបនេះអាចនឹងមិនកើតមាននៅក្នុងទន្លេមេទេ វាអាចកើតមាននៅតំបន់ទឹកនឹង ឬតំបន់ដែលរងឥទ្ធិពលទឹកកល់ពីខ្សែទឹកខាងក្រោម តែប៉ុណ្ណោះ។” ទោះបីជាយ៉ាងណាលោកបានក្រើនរំលឹកថា “ប្រជាពលរដ្ឋគួរតែប្រុងប្រយ័ត្នក្នុងការផ្តល់ទឹកដល់សត្វ ប្រសិនបើទឹកមានពណ៌បៃតងខ្លាំង។”

បើយោងតាមការវិភាគ ការលេចឡើងទឹកពណ៌ខៀវបៃតងក្នុងទន្លេមេគង្គនាពេលបច្ចុប្បន្នអាចនឹងបន្តរហូតដល់លំហូរទឹកទន្លេកើនឡើងវិញ នៅដើមរដូវវស្សាឆ្នាំក្រោយ ដែលតែងតែចាប់ផ្តើមនៅចុងខែឧសភា។ ស្ថានភាពនេះក៏អាចនឹងធូរស្បើយវិញផងដែរ ប្រសិនបើមានការបញ្ចេញបរិមាណទឹកច្រើនពីអាងស្តុកទឹកផ្នែកខាងលើទន្លេមេគង្គ ( ឡានឆាង ) និងពីទំនប់វារីអគ្គិសនីនានាដើម្បីប្រមូលផ្តុំសារជាតុកករ និងធ្វើឲ្យទឹកទន្លេមេគង្គមានពណ៌ត្នោតវិញ។

ការពិនិត្យតាមដានលំហូរទឹករបស់MRC បង្ហាញថាលំហូរទឹកនារដូវប្រាំងបានកើនឡើងក្នុងកំឡុងពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ដោយសារការបញ្ចេញទឹកពីអាងស្តុកទឹកដើម្បីផលិតអគ្គិសនី។

**កំណត់សម្គាល់សម្រាប់និពន្ធនាយក៖**

គណៈកម្មការទន្លេមេគង្គ គឺជាស្ថាប័នអន្តររដ្ឋាភិបាល ដែលមានតួនាទីជំរុញលើកកម្ពស់កិច្ចពិគ្រោះយោបល់ និងកិច្ចសហប្រតិបត្តិការថ្នាក់តំបន់នៅក្នុងតំបន់អាងទន្លេមេគង្គខ្សែទឹកខាងក្រោម ដែលត្រូវបានបង្កើតឡើងក្នុងឆ្នាំ ១៩៩៥ ផ្អែកទៅតាមកិច្ចព្រមព្រៀងទន្លេមេគង្គ រវាងប្រទេសកម្ពុជា ឡាវ ថៃ និងវៀតណាម។ ស្ថាប័ននេះ បំពេញតួនាទីជាវេទិកាថ្នាក់តំបន់សម្រាប់ការទូតទឹក ក៏ដូចជា ជាមជ្ឈមណ្ឌលប្រមូលផ្តុំចំណេះដឹងអំពីការគ្រប់គ្រងធនធានទឹក ដើម្បីការអភិវឌ្ឍន៍តំបន់នេះ ប្រកបដោយចីរភាព។

**-ចប់-**

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖**
លោក មាស សុភក្រ្ត
មន្ត្រីទំនាក់ទំនងជាមួយអ្នកសារព័ត៌មាន
លេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ
អ៊ីម៉ែល៖ sopheak@mrcmekong.org
ទូរសព្ទ៖ +856-21-263263, ភ្ជាប់បន្ត 4072
ទូរសព្ទដៃ៖ +856-20-77779168

###